ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ០៩៨ របក

ខុទ្ទកាល័យសម្តេចតេជោ
នាយករដ្ឋមន្ត្រី
ចូល ថ្ងៃទី 21 ខែ 07 ឆ្នាំ២០20
ម៉ោង 2 H 00

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** សូមអនុញ្ញាតធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជាន់ខ្ពស់ រវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ជាមួយទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ស្តីពីការរៀបចំកម្មវិធីរួមគ្នា ក្រោមមូលនិធិស្ម័គ្រចិត្តពហុភាគីអង្គការសហប្រជាជាតិ។

**យោង** ៖ - ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ លើលិខិតលេខ ៦៨៨ លស ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ

- ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ លើរបាយការណ៍លេខ ០៦០ របក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ
- លិខិតរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាជ្រាបថា បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ខ្ញុំបានដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ជាមួយអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដើម្បីពិភាក្សាអំពីលទ្ធភាពឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លី មធ្យម និងរយៈពេលវែងរបស់ពលករចំណាកស្រុក ក្នុងដំណាក់កាលនៃវិបត្តិជំងឺកូវីដ-១៩ ដោយទទួលបានលទ្ធផលដូចបានគោរពរាយការណ៍ជូន **សម្តេចតេជោ** កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ កន្លងទៅ។

ផ្តើមចេញពីលទ្ធផលនៃកិច្ចប្រជុំខាងលើ ទីស្នាក់ការកណ្តាលអង្គការសហប្រជាជាតិ តាមរយៈសំណើគម្រោងរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានអនុម័តកម្មវិធីរួមគ្នាមួយ ក្រោមមូលនិធិស្ម័គ្រចិត្តពហុភាគីនៃអង្គការសហប្រជាជាតិដើម្បីឆ្លើយតប និងស្តារស្ថានភាពឡើងវិញក្រោយជំងឺកូវីដ-១៩ (UN COVID-19 Response and Recovery Multi-partner Trust Fund) ក្នុងទំហំទឹកប្រាក់ចំនួន ០១ លានដុល្លារសហរដ្ឋអាមេរិក ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលដៅការពារការឆ្លងរាលដាលទៅក្នុងសហគមន៍ជាទ្រង់ទ្រាយធំ និងឆ្លើយតបទៅនឹងផលប៉ះពាល់លើពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់ពីក្រៅប្រទេស ក្នុងស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩។

ផ្អែកលើមូលដ្ឋាននេះ ដោយមានការស្នើសុំពីអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាតាមរយៈលិខិតដូចមានចុះក្នុងយោងខាងលើ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ខ្ញុំបានដឹកនាំកិច្ចប្រជុំជាន់ខ្ពស់

ងក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ជាមួយអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដើម្បីពិភាក្សាអំពីការរៀបចំ និងអនុវត្តកម្មវិធីរួមគ្នានេះ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

កម្មវិធីរួមគ្នានេះ មានរយៈពេល ០៦ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ចុងខែធ្នូ ឆ្នាំ២០២០ ដោយគ្រោងអនុវត្តនៅខេត្តគោលដៅចំនួន០៣ គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប ជាខេត្តមានពលករវិលត្រឡប់ពីក្រៅប្រទេសប្រមាណជាង ៨៨% នៃចំនួនពលករវិលត្រឡប់ពីក្រៅប្រទេសសរុប។

កម្មវិធីរួមគ្នានេះ មានគោលដៅការពារពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់ពីក្រៅប្រទេស និងសហគមន៍របស់ពួកគាត់ ពីហានិភ័យនៃការឆ្លងរាលដាលជាទ្រង់ទ្រាយធំនៃជំងឺកូវីដ-១៩ និងធានាការបន្តផ្តល់សេវាសេដ្ឋកិច្ច-សង្គមចាំបាច់នានាជូនបងប្អូនពលករទេសន្តរប្រវេសន៍ទាំងនោះ ជាមួយលទ្ធផលរំពឹងទុកចំនួន ០៣ គឺ៖

ទី១. ពលករទេសន្តរប្រវេសន៍ដែលបានវិលត្រឡប់ និងសហគមន៍របស់ពួកគាត់ ត្រូវបានការពារពីហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ជាទ្រង់ទ្រាយធំ ព្រមទាំងទទួលបាននូវអត្ថប្រយោជន៍ពីការបន្តផ្តល់សេវាកម្មសេដ្ឋកិច្ច-សង្គមចាំបាច់នានា។

ទី២. ពលករទេសន្តរប្រវេសន៍ដែលបានវិលត្រឡប់ និងសហគមន៍របស់ពួកគាត់ ទទួលបាននូវការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត និងចិត្តសាស្ត្រសង្គម ការសម្រាលហានិភ័យនៃអំពើហិង្សាក្នុងគ្រួសារ និងការគាំពារសុខភាពមាតា-ទារកកាន់តែប្រសើរ។

ទី៣. ពលករទេសន្តរប្រវេសន៍ងាយរងគ្រោះបំផុតដែលបានវិលត្រឡប់ ជាពិសេសស្ត្រីភេទ គ្រួសារដែលមានមេគ្រួសារជាស្ត្រី ទទួលបានអត្ថប្រយោជន៍ពីកញ្ចប់សមាហរណកម្មសេដ្ឋកិច្ចបុគ្គល ដើម្បីអាចបង្កើតឡើងនូវស្ថានភាពជីវភាពថ្មីមួយនៅក្នុងសហគមន៍របស់ពួកគាត់។

កម្មវិធីរួមគ្នានេះ នឹងសហការអនុវត្តដោយទីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាចំនួន ០៤ គឺអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM), មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA), មូលនិធិសហប្រជាជាតិសម្រាប់កុមារ (UNICEF) និងអង្គការសុខភាពពិភពលោក (WHO) ជាមួយក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល រួមមានក្រសួងមហាផ្ទៃ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសុខាភិបាល, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងផែនការ និងក្រសួងកិច្ចការនារី រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ព្រមទាំងយន្តការនានាដែលត្រូវបានបង្កើតឡើងទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងយុទ្ធនាការនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នេះ។

បន្ទាប់ពីបានពិភាក្សាផ្លាស់ប្តូរយោបល់ជុំវិញការរៀបចំ ការសម្របសម្រួល និងការអនុវត្តកម្មវិធីរួមគ្នានេះ អង្គប្រជុំបានឯកភាពគ្នាក្នុងការបង្កើតគណៈកម្មការដឹកនាំកម្មវិធីរួមគ្នាមួយ (Joint Program Steering Committee) ដែលមានសមាសភាពជាថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តគោលដៅទាំង០៣ និងតំណាងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដើម្បីសម្របសម្រួលការអនុវត្តកម្មវិធី ក៏ដូចជាតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងដំណើរការនៃការអនុវត្តកម្មវិធីរួមគ្នានេះ។

ទន្ទឹមនេះ នៅក្នុងកិច្ចប្រជុំ លោកស្រី ផូលីន ថាម៉េស៊ីស (Pauline Tamesis) ប្រធានសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានគូសបញ្ជាក់ថាអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាកំពុងរៀបចំបញ្ចប់សេចក្តីព្រាងផែនការឆ្លើយតបផ្នែកសេដ្ឋកិច្ច-សង្គមមួយ ដើម្បីគាំទ្រការស្តារឡើងវិញនូវសេដ្ឋកិច្ច-សង្គម ដែលឯកសារនេះមានសារសំខាន់សម្រាប់ជាមូលដ្ឋានក្នុងការកៀរគរធនធានពីអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍នានាដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា។

ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំទាំង ០២លើក ដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំសូមគោរពស្នើសុំគោលការណ៍ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដើម្បីបន្តសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងទីភ្នាក់ងារនានានៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាក្នុងការអនុវត្តកម្មវិធីរួមគ្នានេះ និងបន្តដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដើម្បីពិនិត្យអំពីលទ្ធភាពនៃកិច្ចសហប្រតិបត្តិការដទៃទៀត ក្នុងក្របខ័ណ្ឌនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងការដោះស្រាយផលប៉ះពាល់នានាបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាជ្រាបជាសេចក្តីរាយការណ៍ និងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃ ចន្ទ ០១កើត ខែ ទុតិយាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**